មើលវីដេអូ ភាគទី ៣០

# វិនិច្ឆ័យអទិន្នាទានដោយអាការ ៥

ស្កេនដើម្បីមើលមេរៀន

San Sochea Official

១ - **ដោយមូល** មានមូល ៣ គឺ លោភមូល ទោសមូល និងមោហមូលទាំង ៣ មិនអាចកើតព្រមគ្នាក្នុងចិត្តុប្បាទជាមួយគ្នាបានឡើយ កើតម្ដងបានតែ២ប៉ុណ្ណោះ គឺ ៖

- បើលួចដើម្បីបានជារបស់ខ្លួន មានលោភៈ និងមោហៈ ជាមូល កើតក្នុងលោភមូលចិត្ត៨ដួង។
- បើលួចដើម្បីបំផ្លាញអ្នកដទៃឲ្យខូចប្រយោជន៍ ដូចជា លួចដុតផ្ទះ លួចបង្ហូរទឹកស្រែគេចោល ជាដើម មានទោសៈ និងមោហៈ ជាមូល កើតនៅក្នុងទោសមូលចិត្ត២ដួង។

** ដូច្នេះអទិន្នាទាន ដាច់ដោយអកុសលចិត្ត១០ ដួង (វៀរមោហមូលចិត្ត២ដួង)*

បើកើតដោយលោភមូលចិត្ត ៨ ដួង
ក្នុងចិត្តនីមួយៗ មានមូល២ គឺ ៖
មោហមូល និងលោភមូល




បើកើតដោយទោសមូលចិត្ត២ដួង
ក្នុងចិត្តនីមួយៗ មានមូល២ គឺ ៖
មោហមូល និងទោសមូល



២ - ដោយកម្ម ជាកាយកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ២ គឺ កាយទ្វារ និងវចីទ្វារ



លួចដោយខ្លួនឯង

ជាកាយកម្ម កាយទ្វារ



ប្រើគេឲ្យលួច

ជាកាយកម្ម វចីទ្វារ

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ ៖

| | |
|---|---|
| - លួចរបស់ដែលនាំឲ្យម្ចាស់ទ្រព្យខូចប្រយោជន៍ច្រើន | មានទោសច្រើន |
| - លួចរបស់ដែលនាំឲ្យម្ចាស់ទ្រព្យខូចប្រយោជន៍តិច | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ អទិន្នាទានមានអង្គ៥ គឺ ៖

- បរបរិគ្គហិតំ ទ្រព្យមានម្ចាស់ហួងហែងរក្សា
- បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថាទ្រព្យមានម្ចាស់ហួងហែងរក្សា
- ថេយ្យចិត្តំ គិតនឹងលួច
- ឧបក្កមោ ព្យាយាមនឹងលួច
- តេន ហរណំ លួចបានដោយការព្យាយាមនោះ។

** កាលណាគ្រប់អង្គទាំង៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*